**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះសីហនុ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ១២១៣
ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២
សំណុំរឿងស៊ើបសួរលេខ: ៩៨៧ ប្រ.ក
ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២
សំណុំរឿងជំនុំជម្រះលេខ: ៥៦១
ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣
សាលក្រមព្រហ្មទណ្ឌលេខ: ២៣៤/២៧ ក្រ១ "ក"
ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣
ថ្ងៃពុធ ១៣កើត ខែភទ្របទ ឆ្នាំថោះ
បញ្ចស័ក ព.ស ២៥៦៧

# តាំងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តព្រះសីហនុ

បានឃើញ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យ ប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៨/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ ។

បានឃើញ ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខ ២៩១៦ ត.ព.រ/២៣ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ ។

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តព្រះសីហនុ នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ៨ និង៣០នាទី ដែលមានសមាសភាពចូលរួម ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

-ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សា
-លោក [redacted] ជាចៅក្រមប្រឹក្សា
-លោក [redacted] ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញារង

## ក្រឡាបញ្ជីសវនាការ

-លោក [redacted] ជាក្រឡាបញ្ជី

**ដើម្បីជំនុំជម្រះ ៖**

សំណុំរឿងព្រហ្មទណ្ឌលេខ ១២១៣ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] **បញ្ញារិទ្ធ** ភេទប្រុស អាយុ២៣ឆ្នាំ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ មានទីកន្លែងកំណើតនៅសង្កាត់ [redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរ បុគ្គលិក ក្រុមហ៊ុន "ណាហ្គាវើល" នៅលីវ ឪពុកឈ្មោះ [redacted] មនោរក្ស "រស់" ម្តាយឈ្មោះ [redacted] ចាន់ធី "រស់" ជាទីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន។





Scanned with CamScanner

ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៧៤៨ ដបឃខ/ឃ/២២ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តព្រះសីហនុ ។

២-ឈ្មោះ [redacted] **ដារិន** ភេទប្រុស អាយុ២៣ឆ្នាំ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ មានទីកន្លែងកំណើតនៅសង្កាត់ [redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្ថិតនៅផ្ទះជួលលេខ២៨ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ មុខរបរ មន្ត្រីរាជការ នៅលីវ ឪពុកឈ្មោះ [redacted] សុខា "រស់" ម្តាយឈ្មោះ [redacted] សុជាវី "រស់" ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។

ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៧៤៩ដបឃខ/ឃ/២២ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តព្រះសីហនុ ។

ត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយការគាស់ទម្លុះទម្លាយ** ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ ចំណុច២ នៃក្រមព្រហ្មទណ្ឌ។

៣-ឈ្មោះ [redacted] **ហេង** ភេទប្រុស កើតឆ្នាំ១៩៨៥ ជនជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិ១ សង្កាត់ លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មុខរបរ បើកឡានស្ទូច នៅលីវ ឪពុកឈ្មោះ [redacted] ហឿន "រស់" ម្តាយឈ្មោះ [redacted] រ៉ី "រស់" ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន ។

ដីកាបង្គាប់ឱ្យចូលខ្លួនលេខ ០៣២ ត.ព.រ/ឃ/២៣ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តព្រះសីហនុ ។

៤-ឈ្មោះ [redacted] **សុភក្តិ** ភេទប្រុស កើតឆ្នាំ១៩៨៧ ជនជាតិខ្មែរ មានទីកន្លែងកំណើតនៅ [redacted] ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិ១ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មុខរបរ ព្រូឡានស្ទូច នៅលីវ ឪពុកឈ្មោះ [redacted] សារិន "រស់" ម្តាយឈ្មោះ [redacted] អួន "រស់" ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។

ដីកាបង្គាប់ឱ្យចូលខ្លួនលេខ ០៣៣ ត.ព.រ/ឃ/២៣ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តព្រះសីហនុ ។

៥-ឈ្មោះ [redacted] **ប្រុស** ភេទប្រុស កើតឆ្នាំ១៩៧៩ ជនជាតិខ្មែរ មានទីកន្លែងកំណើតនៅ [redacted] ខេត្តកំពត ទីលំនៅបច្ចុប្បន្នស្ថិតនៅខណ្ឌ សែនសុខ រាជធានីភ្នំពេញ មុខរបរ ជាងឡាន ប្រពន្ធឈ្មោះ [redacted] សុផានី "គ្មានកូន" ឪពុកឈ្មោះ [redacted] ហ៊ិន "ស្លាប់" ម្តាយឈ្មោះ [redacted] ផែន "ស្លាប់" ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។

ដីកាបង្គាប់ឱ្យចូលខ្លួនលេខ ០៣១ ត.ព.រ/ឃ/២៣ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តព្រះសីហនុ ។



Scanned with CamScanner

ត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ **សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយការគាស់ទម្លុះទម្លាយ** ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ ,មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

**<u>មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ</u>**

1-លោកមេធាវី [redacted] ការិយាល័យ ក្រុមមេធាវី អ៊ីជីស៊ី សាខាខេត្តព្រះសីហនុ ទីតាំងការិយាល័យលេខ B308 នៃអគារឆ្នេរសមុទ្រខៀវ (ឆ្នេរឯករាជ្យ) ផ្លូវ២ធ្នូ ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ (ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ដារិន និងឈ្មោះ រក្ស បញ្ញារិទ្ធ )។

2-លោកមេធាវី [redacted] ការិយាល័យនៅ ប្រតិភូគណៈមេធាវីខេត្តព្រះសីហនុ (ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហេង , [redacted] សុភក្តិ និងឈ្មោះ តុប ប្រុស )។

**<u>ដើមបណ្តឹងរដ្ឋប្បវេណី</u>**

-ឈ្មោះ [redacted] **ណោង** ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ មុខរបរ អ្នកបកប្រែ អាសយដ្ឋានបច្ចុប្បន្នភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

## ១.អង្គហេតុនៃបណ្តឹងចោទប្រកាន់

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ២១ និង ០០នាទី មានប្រជាពលរដ្ឋម្នាក់ឈ្មោះ [redacted] ណោង ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ បច្ចុប្បន្នស្នាក់នៅភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ បានមកដាក់ពាក្យបណ្តឹងនៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ថា នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ០៥ និង ០០នាទីព្រឹក មានជនសង្ស័យចំនួន០២នាក់ បានជិះរថយន្ត០១គ្រឿងម៉ាក PRIUS ពណ៌ខ្មៅ បានហៅឡានស្ទូចមកលួចស្ទូចឡាន០១គ្រឿង ម៉ាក DODGE CHALLENGER ពណ៌ខ្មៅ (បច្ចុប្បន្នបិតពណ៌ស) មានលេខម៉ាស៊ីន GKH 687491, លេខតួ 2C3CDZAG8KH687491 ពាក់ស្លាកលេខ កម្ពុជា HEAXING5 ដែលជារបស់គាត់(ភូ ណោង) បានខូចទុកនៅខាងមុខផ្ទះដោយសារគ្រោះថ្នាក់ចរាចរណ៍ ដើម្បីរង់ចាំគ្រឿងបន្លាស់ផ្លាស់ប្តូរ។ បន្ទាប់មកសមត្ថកិច្ចបានធ្វើការស្រាវជ្រាវ និងបានឃាត់ខ្លួនតៃកុងឡានស្ទូចចំនួន០២នាក់ រួមមាន ៖ ១.ឈ្មោះ [redacted] សុភក្តិ ភេទប្រុស,២.ឈ្មោះ [redacted] ហេង ភេទប្រុស រួចក៏បន្តសហការជាមួយកម្លាំងអធិការដ្ឋាននគរបាលក្រុងព្រះសីហនុ និងកម្លាំងនាយកដ្ឋានព្រហ្មទណ្ឌរាជធានីភ្នំពេញ និងកម្លាំងការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ទើបឃាត់ខ្លួនបានជនសង្ស័យជាបន្តបន្ទាប់ ចំនួន០២នាក់ រួមមាន៖ ១.ឈ្មោះ [redacted] ដារិន ភេទប្រុស, ២.ឈ្មោះ រក្ស បញ្ញារិទ្ធ ភេទប្រុស (អ្នកទាំងពីរមានសញ្ជាតិដូចខាងលើ) និងម្ចាស់កាហ្វេសឡានម្នាក់ឈ្មោះ [redacted] ប្រុស ភេទប្រុស យកមកសាកសួរនៅ

ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ។ ក្រោយពីធ្វើការស្រាវជ្រាវ និងសាកសួរជនសង្ស័យ ឈ្មោះ [redacted] ដារិន និងឈ្មោះ [redacted] បញ្ញារិទ្ធ បានសារភាពប្រាប់សមត្ថកិច្ចថា ពួកខ្លួនទាំងពីរនាក់ ( សំ ដារិន, រក្ស បញ្ញារិទ្ធ ) ពិតជាបានធ្វើសកម្មភាពលួចយករថយន្តខាងលើប្រាកដមែន និងបានកុហកតៃកុងឡានស្ទូច និងម្ចាស់ការ៉ាសខាងលើថា រថយន្ត០១គ្រឿងម៉ាក DODGE CHALLENGER ពណ៌ខ្មៅ (បច្ចុប្បន្នបិតពណ៌ស) ពាក់ស្លាកលេខ កម្ពុជា HEAXING5 គឺជារបស់ពួកខ្លួន ([redacted] ដារិន, [redacted] បញ្ញារិទ្ធ) ដែលបានគ្រោះថ្នាក់ចរាចរណ៍បុកគ្នានៅខេត្តព្រះសីហនុ ហើយត្រូវយកទៅជួសជុលនៅភ្នំពេញ។

-បានឃើញ ដីកាដំណោះស្រាយលេខ ១៧១ ដ.ជ.ស/យ/២៣ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តព្រះសីហនុ[1] ។

## ២. នាពេលសវនាការ

### ២.១ ការស្តាប់ចម្លើយរបស់ជនជាប់ចោទ:

២.១.១-ជនជាប់ចោទឈ្មោះ [redacted] បញ្ញារិទ្ធ បានឆ្លើយថា: ខ្លួនត្រូវបានសមត្ថកិច្ចចាប់ខ្លួន ដោយសារលួចឡានរបស់គេ ជាមួយឈ្មោះ [redacted] ដារិន ។ នៅថ្ងៃមិនចាំ ខែធ្នូ ឆ្នាំ២០២២ ខ្លួន និងឈ្មោះ [redacted] ដារិន បានជិះឡាន១គ្រឿង ម៉ាក PRIUS ពណ៌ខ្មៅ ផ្លាកលេខ ភ្នំពេញ 2BS-7303 (ជាឡានរបស់ឈ្មោះ [redacted] ដារិន ) ទៅដើរលេងនៅខេត្តព្រះសីហនុ ជាមួយគ្នា។ ពេលដែលមកដល់កំពង់សោម ពួកខ្លួនក៏នាំគ្នាជិះរថយន្តទៅហូបអីជាមួយគ្នា ពេលកំពុងធ្វើដំណើរនោះ ឈ្មោះ [redacted] ដារិន បានឃើញឡាន ០១គ្រឿង ម៉ាក DODGE CHALLENGER ពណ៌ខ្មៅ (បិតពណ៌ស) ដែលមានគ្រោះថ្នាក់ចរាចរណ៍ ចតចោលនៅចិញ្ចើមផ្លូវ ហើយគាត់ប្រាប់ថាស្រឡាញ់ឡាននេះ រួចហើយគាត់ក៏ឆែករកលេខឡានស្ទូចតាមរយៈហ្វេបុក និងទំនាក់ទំនងទៅឡានស្ទូច ជួលក្នុងតម្លៃ ៣០០$ ពេលឡានស្ទូចមកដល់ គាត់ប្រាប់ទៅម្ចាស់ឡានស្ទូចឱ្យជួយដឹកឡាននេះទៅភ្នំពេញ។ ពេលដឹកឡាននេះមកដល់ភ្នំពេញ គាត់ក៏បានទំនាក់ទនងទៅម្ចាស់ការ៉ាស់ នៅម៉ុំគ្រាំងផ្អង់ ហើយឱ្យឡានស្ទូចទំលាក់ឡាននេះនៅទីនោះតែម្តង។

២.១.២-ជនជាប់ចោទឈ្មោះ [redacted] ដារិន បានឆ្លើយថា: ខ្លួន និងឈ្មោះ [redacted] បញ្ញារិទ្ធ ដែលត្រូវមិត្តភក្តិនឹងគ្នា ត្រូវបានសមត្ថកិច្ចចាប់ខ្លួន ដោយបានធ្វើសកម្មភាពលួចឡានរបស់គេនៅខេត្តព្រះសីហនុ ។ នៅថ្ងៃមិនចាំ ខែធ្នូ ឆ្នាំ២០២២ ខ្លួនជាមួយនឹងឈ្មោះ [redacted] បញ្ញារិទ្ធ បានជិះតាមផ្លូវចេញពីកន្លែងហូបអី ពេលនោះក៏បានប្រទះឃើញរថយន្ត១គ្រឿង ម៉ាក DODGE CHALLENGER ពណ៌ខ្មៅ ប៉ុន្តែបិតស្កុតពណ៌ស ពុំឃើញមានស្លាកលេខនោះទេ និងមិនមានចាក់សោរដែរ បានចតចោលនៅចិញ្ចើមផ្លូវ មានបុកខូចផ្នែកខាងមុខ គ្របតង់ចោល ។ ខ្លួនក៏ទំនាក់

[1] ដីកាដំណោះស្រាយលេខ ១៧១ ដ.ជ.ស/យ/២៣ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តព្រះសីហនុ(២៨/០៦) ។



Scanned with CamScanner

ទំនងឡានស្ទូច ដែលស្គាល់លេខតាមរយៈហ្វេសបុក មកស្ទូចឡាននោះ ក្នុងតម្លៃ ៣០០$ រួចដឹកតាមផ្លូវល្បឿនលឿន យកមកភ្នំពេញ ពេលឡានស្ទូចមកដល់ ម្ចាស់ឡានស្ទូចក៏បានសួរពួកខ្លួនថា មិនធ្វើនៅកំពង់សោម ខ្លួនក៏បានប្រាប់គាត់វិញថា ការ៉ាស់នៅកំពង់សោមគេមិនធ្វើឱ្យ ហើយឡាននេះជារបស់ខ្លួន ។ ពេលដឹកមកដល់ការ៉ាស់នៅភ្នំពេញ ម្ចាស់ការ៉ាស់បានសួរពួកខ្លួនថា ឡាននេះជារបស់អ្នកណា ខ្លួនក៏បានប្រាប់គាត់វិញថា ជាឡានរបស់បងខ្លួន បុកនៅកំពង់សោម គ្មានជាងធ្វើ។ ខ្លួនជាអ្នកផ្ដើមគំនិតក្នុងការលួចឡាននេះ ឈ្មោះ រិទ្ធ មិនដឹងថាខ្លួនលួចឡានគេទេ ដោយពេលទៅស្ទូចយកឡាននោះ ខ្លួនប្រាប់ឈ្មោះ[redacted] បញ្ញារិទ្ធ ថាជាឡានរបស់បងខ្លួន។

*២.១.៣-តុលាការបង្គាប់ឱ្យក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ*[redacted] *ហេង នៅដំណាក់កាលសមត្ថកិច្ច ដែលមានខ្លឹមសារថាៈ* នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ០៣ និង ០០នាទីទាបភ្លឺ ឈ្មោះ ផល (ធ្លាប់រកស៊ីឡានស្ទូចជាមួយគ្នា) គាត់ស្នាក់នៅរាជធានីភ្នំពេញ បានទាក់ទងមកខ្លួនតាមលេខទូរស័ព្ទ ០១២ ២០៧ ៣៣០ ដើម្បីរកឡានស្ទូចថាមានឡានខូចនៅខេត្តព្រះសីហនុ មានគេពឹងឱ្យគាត់ជួយរកឡានឱ្យ ពេលនោះខ្លួនបានសួរទៅគាត់ថាស្ទូចពីណាទៅណា គាត់ថាស្ទូចពីខេត្តព្រះសីហនុយកទៅភ្នំពេញ ពេលនោះគាត់ក៏បានឱ្យលេខទូរស័ព្ទអ្នកដែលរកឡានស្ទូចនោះមកឱ្យខ្លួន ហើយគាត់បានប្រាប់ថា គាត់កំពុងនៅទីតាំងឡានខូចនោះ នៅខេត្តព្រះសីហនុ មានលេខទូរស័ព្ទ ០១១ ៤០១ ៤៤៤, ០១១ ២៥៩ ៦៦០ ពេលនោះខ្លួនក៏បានទាក់ទងទៅលេខនោះ ហើយបាននិយាយតំលៃជាមួយម្ចាស់លេខទូរស័ព្ទនោះ គាត់បានឱ្យខ្លួន២៥០$(ពីរយហាសិបដុល្លាអាមេរិក) តែខ្លួនទាគាត់ ៣០០$(បីរយដុល្លាអាមេរិក) ពេលនោះគាត់ក៏យល់ព្រម ហើយគាត់បានផ្ញើរ Location ទីតាំងកន្លែងគាត់ខូចឡានតាមប្រព័ន្ធតេលេក្រាម នៅមុំសាលារៀនឈ្មោះ វេស្ទើន ស្ថិតនៅភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ពេលនោះខ្លួនក៏បានបើកឡានចេញពីម្តុំឃ្លាំងលើ ស្ថិតនៅភូមិ១ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ចេញទៅយកឡានខូចនោះជាមួយព្រូឡានរបស់ខ្លួនឈ្មោះ[redacted]សុកក្តិ ដោយជិះឡាន១គ្រឿងម៉ាក HYUNDAI ពណ៌ស ស្លាកលេខ 3B-3590 (ប្រភេទឡានស្ទូច៥តោន) ជាឡានរបស់ខ្លួន និងឈ្មោះ សុកក្តិ ពេលទៅដល់ទីនោះ ខ្លួនបានជួប និងបុរស២នាក់ ជាជនជាតិខ្មែរ ក្នុងនោះ១នាក់ពាក់ឯកសណ្ឋានសមត្ថកិច្ច និង១នាក់ទៀត ពាក់ស៊ីវិលធម្មតា(មិនធ្លាប់ស្គាល់) គាត់បានប្រាប់ថា គាត់ជាម្ចាស់ឡាននោះម៉ាក DODGE CHALLENGER ពណ៌ស ស្លាកលេខ កម្ពុជា HEAXING5 ដែលឱ្យខ្លួនស្ទូចយកទៅភ្នំពេញដើម្បីយកទៅធ្វើ គាត់បានប្រាប់ថាធ្វើនៅខេត្តព្រះសីហនុថ្លៃពេក ចឹងបានឱ្យដឹកយកទៅធ្វើនៅរាជធានីភ្នំពេញ បាន

ប្រហែលជាកន្លះម៉ោង ខ្លួនក៏បានស្ទូចឡាននោះដាក់មកលើឡានរបស់ខ្លួន ចេញទៅភ្នំពេញ ហើយពួកគាត់បានប្រាប់ថា ចេញទៅមុនទៅចាំគាត់ទៅតាមក្រោយ ពេលទៅដល់ភ្នំពេញចាំទាក់ទងគ្នាប្រាប់កន្លែងដាក់ឡាន។ រហូតដល់ម៉ោង ០៩ និង០០នាទី ខ្លួនបានទៅដល់ភ្នំពេញ ពួកគាត់បាននាំខ្លួនយកឡានទៅទំលាក់ នៅការ៉ាស់ឡាន១កន្លែង នៅម្តុំវត្តក្រាំងធ្នង់ ស្ថិតនៅសង្កាត់ក្រាំងធ្នង់ រាជធានីភ្នំពេញ ពួកគាត់បានជិះឡានម៉ាក PRUIS ពណ៌ខ្មៅ (មិនចាំស្លាកលេខ) តាមពីក្រោយឡានខ្លួន ពេលដែលទំលាក់ឡាននោះហើយ គាត់បានបាញ់លុយឱ្យមកខ្លួនតាមគណនី ABA ដែលមានឈ្មោះ [redacted] DARIN លេខគណនី: 225566000 ចំនួន ៣៤០$ (បីរយសែសិប)ដុល្លារអាមេរិក បូកទាំងឡើងផ្លូវល្បឿនលឿន ពេលដែលទទួលបានលុយហើយ ខ្លួនក៏ត្រឡប់មកវិញជាមួយព្វឡានរបស់ខ្លួន។ រហូតនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ១៦ និង០០នាទី ខ្លួនកំពុងនៅម្តុំឃ្លាំងលើ ស្រាប់តែមានបុរសម្នាក់ទាក់ទងមកខ្លួន បានសួរខ្លួនថា មានទៅស្ទូចឡាន១គ្រឿង ពណ៌សទេ ហើយអ្នកណាឱ្យស្ទូចឡាននោះ នៅមុខការ៉ាស់ ម្តុំសាលារៀនវេសស្ទើន កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ០៣ និង៣០នាទី ពេលនោះខ្លួនក៏បានប្រាប់ថា ខ្លួនបានទៅស្ទូចមែន ព្រោះម្ចាស់ឡានជាអ្នកឱ្យខ្លួនស្ទូច ពេលនោះគាត់ក៏បានប្រាប់វិញថា ឥឡូវមេរបស់គាត់ជាម្ចាស់ឡាននោះបានបាត់ឡានហើយ ភ្លាមៗនោះខ្លួនក៏បានទាក់ទងទៅសួរអ្នកឱ្យខ្លួនស្ទូចឡាននោះ សួរថាមានម្ចាស់ឡានម្នាក់ទៀត ទាក់ទងមកខ្លួនសួររឿងឡានដែលឱ្យខ្លួនស្ទូចនោះ ស្រាប់តែគាត់បានបិទទូរស័ព្ទទាក់ទងមិនបានរហូតតែម្តង។ ពេលនោះខ្លួនត្រូវសមត្ថកិច្ច នាំខ្លួនមកសួរនាំនៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ក័យពេកក៏បាននាំម្ចាស់ឡានម្នាក់ទៀត ទៅកន្លែងដែលខ្លួនទំលាក់ឡាននោះនៅភ្នំពេញ ។

២.១.៤-*តុលាការបង្គាប់ឱ្យក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] សុភក្តិ នៅដំណាក់កាលសមត្ថកិច្ច ដែលមានខ្លឹមសារថា:* នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ០៣ និង៣០នាទីទាបភ្លឺ មេរបស់ខ្លួនឈ្មោះ [redacted] ហេង បានទាក់ទងមកខ្លួនដើម្បីយកឡានស្ទូចថា មានឡានខូចនៅខេត្តព្រះសីហនុ ស្ទូចពីខេត្តព្រះសីហនុយកទៅភ្នំពេញ ពេលនោះមេរបស់ខ្លួនគាត់ក៏បានទាក់ទងទៅលេខទូរស័ព្ទ អ្នកដែលរកឡានស្ទូចនោះ ហើយគាត់បានប្រាប់ថា ម្ចាស់ឡានគាត់កំពុងនៅទីតាំងឡានខូចនោះ នៅខេត្តព្រះសីហនុ មានលេខទូរស័ព្ទ ០១១៤០១៤៤៤ ,០១១២៥៩៦៦០ ពេលនោះគាត់ក៏បានទាក់ទងទៅលេខនោះ ហើយបាននិយាយតំលៃជាមួយម្ចាស់លេខទូរស័ព្ទនោះ គាត់បានឱ្យពួកខ្លួន២៥០$ (ពីរយហាសិបដុល្លាអាមេរិក) តែខ្លួនទាគាត់ ៣០០$(បីរយដុល្លាអាមេរិក) ពេលនោះគាត់ក៏យល់ព្រម ហើយគាត់បានផ្ញើរ Location ទីតាំងកន្លែងគាត់ខូចឡាន តាមប្រព័ន្ធតេលេក្រាមនៅម្តុំសាលារៀនឈ្មោះ វេស្ទើន ស្ថិតនៅភូមិ២



Scanned with CamScanner

សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ពេលនោះខ្លួនក៏បានបើកឡានចេញពីម៉ុឃ្លាំងលើ ស្ថិតនៅភូមិ១ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ចេញទៅយកឡានខូចនោះជាមួយមេរបស់ខ្លួន ដោយជិះឡាន១គ្រឿងម៉ាក HYUNDAI ពណ៌ស ស្លាកលេខ 3B-3590 (ប្រភេទឡានស្ទូច៥តោន) ជាឡានរបស់មេខ្លួន ពេលទៅដល់ទីនោះ ខ្លួនបានជួបនិងបុរស២នាក់ ជាជនជាតិខ្មែរ ម្នាក់ពាក់ឯកសណ្ឋានជាសមត្ថកិច្ច និងម្នាក់ទៀតពាក់ស៊ីវិលធម្មតា(មិនធ្លាប់ស្គាល់) គាត់បានប្រាប់ថា គាត់ជាម្ចាស់ឡាននោះម៉ាក DODGE CHALLENGER ពណ៌ស ស្លាកលេខ កម្ពុជា HEAXING5 ដែលឱ្យខ្លួនស្ទូចយកទៅភ្នំពេញដើម្បីយកទៅធ្វើ គាត់បានប្រាប់ថា ធ្វើនៅខេត្តព្រះសីហនុថ្លៃពេក ចឹងបានឱ្យដឹកយកទៅធ្វើនៅរាជធានីភ្នំពេញ បានប្រហែលជាកន្លះម៉ោង ខ្លួនក៏បានស្ទូចឡាននោះដាក់មកលើឡានរបស់ខ្លួនចេញទៅភ្នំពេញ ហើយពួកគាត់បានប្រាប់ថា ចេញទៅមុនទៅចាំគាត់ទៅតាមក្រោយ ពេលទៅដល់ភ្នំពេញចាំទាក់ទងគ្នាប្រាប់កន្លែងដាក់ឡាន។ រហូតដល់ម៉ោង ០៩ និង ០០ នាទី ខ្លួនបានទៅដល់ភ្នំពេញ ពួកគាត់បាននាំខ្លួនយកឡានទៅទំលាក់នៅការ៉ាស់ឡាន១កន្លែង នៅម៉ុវត្តក្រាំងធ្នង់ ស្ថិតនៅសង្កាត់ក្រាំងធ្នង់ រាជធានីភ្នំពេញ ពួកគាត់បានជិះឡាន១គ្រឿងម៉ាក PRUIS ពណ៌ខ្មៅ (មិនចាំស្លាកលេខ) តាមពីក្រោយខ្លួន ពេលដែលទំលាក់ឡាននោះហើយ គាត់បានបាញ់លុយឱ្យមកមេខ្លួនតាមគណនី ABA ដែលមានឈ្មោះ [redacted] DARIN លេខគណនី 225566000 ចំនួន៣៦០$(បីរយសែសិបដុល្លាអាមេរិក) បូកទាំងឡើងផ្លូវល្បឿនលឿន ពេលដែលទទួលលុយបានហើយ ខ្លួននិងមេរបស់ខ្លួនក៏បានត្រលប់មកវិញ ។

២.១.៥-*តុលាការបង្គាប់ឱ្យក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ* [redacted] *ប្រុស នៅដំណាក់កាលសមត្ថកិច្ច ដែលមានខ្លឹមសារថា:* នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ០៨ និង ០០នាទី ឈ្មោះ [redacted] ដារិន ប្រើប្រាស់លេខទូរស័ព្ទ ០៩៣ ៣០១០០៧ បានទាក់ទងមកខ្លួនប្រាប់ថាគាត់មានឡាន១គ្រឿងម៉ាក DODGE CHALLENGER ពណ៌ខ្មៅ (បិទពណ៌ស) បុកគ្រោះថ្នាក់ចរាចរណ៍នៅខេត្តព្រះសីហនុ ដាច់កង់១គ្រាប់ យកមកធ្វើនៅភ្នំពេញ ដាក់ឡានស្ទូចយកមកឱ្យជួលជុល ពេលនោះខ្លួនក៏បានប្រាប់ទីតាំងការ៉ាស់ឡានរបស់ខ្លួនឱ្យទៅគាត់ ស្ថិតនៅម៉ុវត្តក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ពេលលនោះគាត់រកទីតាំងមិនឃើញ ខ្លួនក៏បានដាក់ទីតាំង Location តាមប្រព័ន្ធតេលេក្រាមទៅឱ្យគាត់ បានប្រហែលជា១៥នាទី គាត់បានជិះឡាន១ គ្រឿងម៉ាក PRIUS ពណ៌ខ្មៅ ស្លាកលេខ ភ្នំពេញ 2BS-7303 (មានគ្នា២នាក់ ប្រុស) និងឡាន១គ្រឿងទៀតជាប្រភេទឡានស្ទូច ដែលដឹកឡានដែលត្រូវយកមកទំលាក់ធ្វើនៅការ៉ាស់របស់ខ្លួន ពេលមកដល់ពួកគាត់ក៏បានទំលាក់ឡាននោះនៅមុខការ៉ាស់ ហើយរុញចូលទៅក្នុង៖

កាហ៊ស់ ហើយម្ចាស់ឡានស្ទូចនោះ ក៏បានបើកចេញពីកាហ៊ស់ខ្លួនទៅវិញ ភ្លាមៗនោះឈ្មោះ [redacted] ដារិន គាត់ក៏បានបកស្កុតឡានពណ៌ស នោះចេញ ឱ្យឃើញពណ៌ខ្មៅវិញ ហើយបាននិយាយជាមួយខ្លួនរឿងថ្លៃជួលជុលឡាននោះ តែខ្លួនបានប្រាប់ទៅគាត់វិញថា មិនមានគ្រឿងផ្លាស់ប្តូរទេ វាជាប្រភេទឡានទំនើបនៅស្រុកខ្មែរមិនមានគ្រឿងទេ ខ្លួនបានប្រាប់គាត់ទៀតថា ឱ្យកុម្ម៉ង់គ្រឿងខ្លួនឯងទៅ ខ្លួនជួយជូរនិងជួលជុលឱ្យ ព្រោះកាហ៊ស់របស់ខ្លួនទទួលតែបាញ់ថ្នាំ តោននិងជួលជុលម៉ាស៊ីនទេ ពេលនោះគាត់បានប្រាប់វិញថាចាំគាត់ជាអ្នកកុម្ម៉ង់គ្រឿងមក ឱ្យខ្លួនជួយជូរឱ្យគិតថ្លៃពលកម្មតាមនឹងទៅ ហើយគាត់ក៏បានត្រលប់ទៅវិញ ។ លុះស្អែកឡើងនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ០៨ និង ៣០ នាទី ស្រាប់តែសមត្ថកិច្ចមកដល់កាហ៊ស់ឡានរបស់ខ្លួន ប្រាប់ថាមានគេបាត់ឡានអីលូវឃើញនៅក្នុងកាហ៊ស់ឡានរបស់ខ្លួន ពេលនោះខ្លួនបានប្រាប់ពីរឿងដែលមានគេយកឡានមកផ្ញើ នៅកាហ៊ស់របស់ខ្លួន កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០២២ ទៅសមត្ថកិច្ច ។ ពេលនោះខ្លួនក៏បានទាក់ទងទៅឈ្មោះ [redacted] ដារិន តែគាត់មិនបានលើកទូរស័ព្ទទេ រហូតដល់ម៉ោង ១៣ និង ០០នាទី ឈ្មោះ [redacted] ដារិន គាត់ក៏បានទូរស័ព្ទមកវិញ ហើយខ្លួនក៏បានសួរគាត់ថាឡានមានបញ្ហាអីមែន បានជាមានសមត្ថកិច្ចមកដល់កាហ៊ស់របស់ខ្លួនច្រើនម្ល៉េះ ពេលនោះគាត់បាននិយាយថាបើមានគេមកយកឡានឱ្យគេទៅ រួចក៏បិទទូរស័ព្ទតែម្តង។ លុះស្អែកឡើងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ ខ្លួនកំពុងតែនៅកាហ៊ស់របស់ខ្លួន ស្រាប់តែមានសមត្ថកិច្ចមកដល់ ឱ្យស្ទូចឡានដែលឈ្មោះ [redacted] ដារិន និងឈ្មោះ [redacted] បញ្ញារិទ្ធ យកមកផ្ញើនៅកាហ៊ស់ខ្លួននោះ យកទៅខេត្តព្រះសីហនុឱ្យម្ចាស់ដើមគេវិញ ហើយបានបញ្ជូនខ្លួនមកកាន់ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុដើម្បីសួរនាំ ។

**២.២ ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី:** *តុលាការបង្គាប់ឱ្យក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណេង នៅដំណាក់កាលសមត្ថកិច្ច ដែលមានខ្លឹមសារថា:* នៅអំឡុងខែតុលា ឆ្នាំ២០២២ ខ្លួនមានរថយន្ត១គ្រឿង ម៉ាក DODGE CHALLENGER ពណ៌ខ្មៅ (បច្ចុប្បន្ននេះខ្លួនបិតពណ៌ស៊ីម៉ង់) មានលេខម៉ាស៊ីន GKH687491, លេខតួ 2C3CDZAG8KH 687491 ពាក់ផ្លាកលេខ កម្ពុជា HEAXING5 បានជួលឱ្យជនជាតិចិន ០១នាក់ កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២២ ក៏មានគ្រោះថ្នាក់ចរាចរណ៍ នៅមុំសណ្ឋាគារស៊ីហ៊ូ ស្ថិតនៅភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ហើយខ្លួនបានដោះស្រាយនៅកន្លែងសមត្ថកិច្ចរួចរាល់ហើយ ។ បន្ទាប់មកខ្លួនក៏បានស្ទូចឡានរបស់ខ្លួន យកទៅដាក់នៅកាហ៊ស់ឡានចាស់របស់ខ្លួន ស្ថិតនៅភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដោយរង់ចាំគ្រឿងផ្លាស់ប្តូរ ដោយសភាពរថយន្តរបស់ខ្លួនត្រូវបានដោះកងមុខខាងស្តាំចេញទៀតផង។ ក្រោយមកនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២

វេលាម៉ោង ១៣ និង០០នាទី នៅពេលដែលគ្រឿងបន្លាស់រថយន្តមកដល់ ខ្លួនក៏យកទៅប្តូរ ស្រាប់តែមិនឃើញរថយន្តនោះទេ។ បន្ទាប់ពីត្រួតពិនិត្យកាមេរ៉ាសុវត្ថិភាព ឃើញថា នៅថ្ងៃខែឆ្នាំដដែល វេលាម៉ោង ៣ទៀបភ្លឺ មានរថយន្តស្លាប់០១គ្រឿង បានមកស្ទូចយករថយន្តរបស់ខ្លួន និងមានមនុស្សចំនួន២នាក់ ជិះរថយន្តចំនួន ០១គ្រឿង ម៉ាក PRIUS ពណ៌ខ្មៅ បានដោះស្លាកលេខរថយន្តរបស់ខ្លួនកាន់នៅដៃ និងបានបញ្ជាឱ្យរថយន្តស្ទូចៗយករថយន្តរបស់ខ្លួនចេញទៅ។

**២.៣ តុលាការបង្គាប់ឱ្យក្រឡាបញ្ជីអានកំណត់ហេតុចាប់យកវត្ថុតាងក្នុងបទល្មើសជាក់ស្តែង ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០២២ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ។**

**២.៤ ការស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ:** ផ្អែកតាមការសួរដេញដោលនាពេលសវនាការកាលបរិច្ឆេទអាចមានការភ័ណ្ឌច្រឡំ ដោយឡែកអំពើប្រព្រឹត្តជនជាប់ចោទឈ្មោះ [redacted] ដារិន ជាអ្នកផ្តើមគំនិតយកឡានស្ទូច និងស្ទូចយកឡានទៅផ្ញើនៅភ្នំពេញ ក្នុងតម្លៃ ៣០០$ ការឆ្លើយមានភស្តុតាងគ្រប់គ្រាន់ ។ ជនជាប់ចោទឈ្មោះ [redacted] ដារិន បានឆ្លើយបន្ថែមទៀតថា ការប្រព្រឹត្តអំពើលួចនេះ ជនជាប់ចោទឈ្មោះ [redacted] បញ្ញារិទ្ធ ពុំបានដឹងទេ ខ្លួនប្រាប់ថាជារថយន្តរបស់បងខ្លួន រីឯជនជាប់ចោទឈ្មោះ [redacted] បញ្ញារិទ្ធ បានឆ្លើយថាមិនដឹងនោះ គឺមិនពិតទេ ការដែលជនជាប់ចោទឈ្មោះ [redacted] បញ្ញារិទ្ធ ឆ្លើយថាមិនដឹង គឺជាការលាក់បាំង ហើយជនជាប់ចោទឈ្មោះ [redacted] បញ្ញារិទ្ធ ក៏បានសារភាពថា ខ្លួនបានដឹង និងបានចូលរួមធ្វើសកម្មភាពនេះផងដែរ។ ចំពោះអង្គហេតុខាងលើ តំណាងអយ្យការសុំធ្វើការកែប្រែពីបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយការគាស់ទម្លុះទម្លាយ** តាមបញ្ញត្តិមាត្រា ៣៥៣ , ៣៥៧ នៃក្រមព្រហ្មទណ្ឌ មកជាបទ **អំពើលួច** តាមបញ្ញត្តិមាត្រា ៣៥៣,៣៥៦ នៃក្រមព្រហ្មទណ្ឌ វិញ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] ហេង ,ជនជាប់ចោទឈ្មោះ [redacted] សុភក្តិ និងជនជាប់ចោទឈ្មោះ [redacted] ប្រុស ពុំបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ សុំឱ្យរួចផុតបទចោទ។

**២.៥ ការស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ការពារសិទ្ធជនជាប់ចោទឈ្មោះ [redacted] ដារិន និងជនជាប់ចោទឈ្មោះ [redacted] បញ្ញារិទ្ធ ថា:** ផ្អែកតាមអង្គសវនាកា និងតាមការបកស្រាយបំភ្លឺ តាមដំណាក់កាលនីមួយៗរបស់កូនក្តីខ្លួនទាំងពីរនាក់ឃើញថា៖ តំណាងអយ្យការបានធ្វើការចោទប្រកាន់ទៅលើកូនក្តីខ្លួនទាំង ២នាក់ ពីបទ: *លួចមានស្ថានទម្ងន់ទោសដោយការកាប់គាស់ទម្លុះទម្លាយ* ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ គឺកូនក្តីខ្លួនទាំងពីរនាក់ ពិតជាបានលួចយករថយន្តរបស់ជនរងគ្រោះឈ្មោះ [redacted] ណោង ប្រាកដមែន ប៉ុន្តែការលួចរបស់កូនក្តីខ្លួននេះ គឺពុំបានប្រព្រឹត្តសកម្មភាពណាមួយ ក្នុងការកាប់គាស់ទម្លុះទម្លាយ ដើម្បីលួចយករថយន្តនោះឡើយ ។ ការកាប់គាស់ទម្លុះទម្លាយនៅពេលនេះ គឺមានន័យថា គឺជាអំពើបង្ខំធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញគ្រឿងបិទទ្វារ ឬ របង ទោះបីមានប្រភេទ

យ៉ាងណាក៏ដោយ ។ (មាត្រា ៧៩នៃក្រមព្រហ្មទណ្ឌ) ហើយនៅក្នុងក្រមព្រហ្មទណ្ឌនោះ បានចែងទៀតផងដែរថា ចាត់ទុកដូចជាការកាប់គាស់ទម្លុះទម្លាយដែរនូវ៖ ការប្រើប្រាស់កូនសោក្លែង ,ការប្រើប្រាស់កូនសោដែលបានមកដោយឧបាយកលទុច្ចរិត ,ការប្រើប្រាស់គ្រប់ឧបករណ៍ដើម្បីធ្វើឱ្យគ្រឿងបិទ មានដំណើរការដោយគ្មានការបង្ខំ ការខូចខាត ឬ ការបំផ្លិចបំផ្លាញទេ ។ ដូច្នេះការដែលកូនក្តីខ្លួនបានជួលរថយន្តស្ទូច ទៅស្ទូចយករថយន្តដែលខូចបើកមិនកើត ដើម្បីយកទៅឱ្យជាងជួសជុល ទោះបីជាបានប្រើឧបករណ៍ក្នុងការធ្វើសកម្មភាពស្ទូចរថយន្តនោះក៏ដោយ ក៏ពុំបានប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយ ក្នុងអំពើលួចនោះដែរ។ មួយវិញទៀត ស្លាកលេខរថយន្ត ដែលកូនក្តីខ្លួនឈ្មោះ [redacted] ដារិន បានយកចេញពីតួរថយន្តមកកាន់នឹងដៃនោះ ក៏ពុំមានការកាប់គាស់ទម្លុះទម្លាយចេញពីរថយន្តនោះដែរ គឺរថយន្តពុំមានចាក់សោអ្វីទាំងអស់។ ការចោទប្រកាន់របស់តំណាងអយ្យការមកលើកូនក្តីខ្លួនពីបទ: **អំពើលួចមានស្ថានទម្ងន់ទោសដោយការកាប់គាស់ទម្លុះទម្លាយ** តាមបញ្ញត្តិមាត្រា ៣៥៣ និង មាត្រា៣៥៧ ចំណុច២ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ នោះ គឺជាការចោទប្រកាន់ពុំត្រឹមត្រូវតាមច្បាប់ឡើយ។ តាមពិតអំពើប្រព្រឹត្តរបស់កូនក្តីខ្លួន គឺជាអំពើលួចធម្មតា តាមបញ្ញត្តិមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ គ្មានការកាប់គាស់ទម្លុះទម្លាយមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ៣៥៧ ចំណុច២ នោះទេ ហើយតំណាងអយ្យការក៏បានប្តឹងសុំកែប្រែបទចោទនាពេលសវនាការពីបទ **លួចមានស្ថានទម្ងន់ទោសដោយការកាប់គាស់ទម្លុះទម្លាយ** មកជាបទ លួច តាមបញ្ញត្តិមាត្រា ៣៥៦ វិញដែរ។ ដូច្នេះខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] បញ្ញារិទ្ធ និងឈ្មោះ [redacted] ដារិន ស្នើសុំ ឯកឧត្តមប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រុមប្រឹក្សាជំនុំជម្រះទាំងមូល មេត្តាធ្វើការកែប្រែបទចោទ គឺពីបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយការកាប់គាស់ទម្លុះទម្លាយ** តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ ចំណុច២ នៃក្រមព្រហ្មទណ្ឌ ទៅជាបទ **អំពើលួច** ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ វិញ ។

**២.៦ ការស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] ប្រុស , ជនជាប់ចោទឈ្មោះ [redacted] ហេង និងជនជាប់ចោទឈ្មោះ [redacted] សុខគ្គី ថា:** កូនក្តីខ្លួនឈ្មោះ [redacted] ប្រុស ជាអ្នករកស៊ីបើកការ៉ាស់ជួសជុលឡានតែប៉ុណ្ណោះ។ រីឯកូនក្តីឈ្មោះ [redacted] ហេង និងឈ្មោះ [redacted] សុកគ្គិ គឺពួកគាត់រកស៊ីជាអ្នកស្ទូចរថយន្ត ពាក់ព័ន្ធនឹងការលួចរថយន្តនោះ កូនក្តីខ្លួនទាំង៣នាក់ពុំបានដឹងឡើយ។ ដូច្នេះខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំង៣នាក់ខាងលើ ស្នើសុំឱ្យតុលាការលើកលែងចោទប្រកាន់ឱ្យកូនក្តីខ្លួនទាំង៣នាក់ខាងលើផង។



Scanned with CamScanner

២.៧ ការស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] បញ្ញារិទ្ធ និងឈ្មោះ [redacted] ដារិន: សុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យពួកខ្លួនផង ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណាចម្លើយជនជាប់ចោទនៅក្រៅឃុំ

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្ដុតាងនានាក្នុងសំណុំរឿង

-បានឃើញ កំណត់ហេតុជំនុំជម្រះចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តព្រះសីហនុ ។

## ៣.ផ្នែកសំអាងហេតុ

## ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់
## សាលាដំបូងខេត្តព្រះសីហនុ យល់ឃើញថា ៖

៣.១ តាមដីកាដំណោះស្រាយលេខ ១៧១ ដ.ដ.ស/យ/២៣ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តព្រះសីហនុ[2] ចៅក្រមស៊ើបសួរបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] បញ្ញារិទ្ធ ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] ដារិន ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មកជំនុំជម្រះពីបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយការគាស់ទម្លុះទម្លាយ** ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ ចំណុច២ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] ហេង ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ ,ឈ្មោះ [redacted] សុភក្ដិ ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ប្រុស ភេទប្រុស អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ មកជំនុំជម្រះពីបទ **សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយការគាស់ទម្លុះទម្លាយ** ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃ▪

2 ដីកាដំណោះស្រាយលេខ ១៧១ ដ.ដ.ស/យ/២៣ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តព្រះសីហនុ(ឧ៨/០៦) ។



Scanned with CamScanner

ទី១៧ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ , មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣.២ អំពើល្មើសដែលរងការចោទប្រកាន់ត្រូវបានប្រព្រឹត្តឡើង នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ ដោយជនជាប់ចោទបានយកទ្រព្យសម្បត្តិ(រថយន្ត) អ្នកដទៃ ដោយពុំបានយល់ព្រមពីម្ចាស់ទ្រព្យសម្បត្តិ ដូច្នេះអំពើនេះត្រូវស្ថិតក្នុងវិសាលភាព នៃក្រមព្រហ្មទណ្ឌ ។

៣.៣ តាមរបាយការណ៍លេខ ៩០៥ រ.ប.ក/២២ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានបញ្ជាក់ថា: នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ២១ និង០០នាទី មានប្រជាពលរដ្ឋមកដាក់ពាក្យបណ្តឹង នៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ថា នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ៥ និង០០នាទីព្រឹក មានជនសង្ស័យ ០២នាក់ បានជិះរថយន្ត០១គ្រឿង ម៉ាក PRIUS ពណ៌ខ្មៅ បានហៅឡានស្ទូចមកលួចស្ទូចឡាន០១គ្រឿង ម៉ាក DODGE CHALLENGER ពណ៌ខ្មៅ (បច្ចុប្បន្ននេះបិតពណ៌ស) មានលេខម៉ាស៊ីន GKH687491, លេខតួ 2C3CDZAG8KH687491 ពាក់ស្លាកលេខ កម្ពុជា HEA XING5 ដែលជារបស់គាត់បានខូចទុកនៅខាងមុខផ្ទះ ដោយសារគ្រោះថ្នាក់ចរាចរណ៍ ដើម្បីរង់ចាំគ្រឿងបន្លាស់ផ្លាស់ប្តូរ។ បន្ទាប់មកសមត្ថកិច្ចបានធ្វើការស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ ក៏ឃាត់ខ្លួនតៃកុងឡានស្ទូច ចំនួន០២នាក់ រួចក៏បន្តសហការជាមួយកម្លាំងអធិការដ្ឋាននគរបាលក្រុងព្រះសីហនុ និងកម្លាំងនាយកដ្ឋាន ព្រហ្មទណ្ឌរាជធានីភ្នំពេញ និងកម្លាំងការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ទើបឃាត់ខ្លួនបានជនសង្ស័យជាបន្តបន្ទាប់ ចំនួន០២នាក់ និងម្ចាស់ការ៉ាសឡាន ០១នាក់ យកមកសាកសួរនៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ។ ក្រោយពីធ្វើការស្រាវជ្រាវ និងសួរនាំជនសង្ស័យរួចរាល់បានឱ្យ ដឹងថា: ជនសង្ស័យចំនួន០២នាក់ បានសារភាពប្រាប់សមត្ថកិច្ចថា ពួកគេទាំង០២នាក់ បាននាំគ្នាមកធ្វើសកម្មភាពលួចយករថយន្តខាងលើ ពិតប្រាកដមែន និងបានកុហក់តៃកុងឡានស្ទូច និងម្ចាស់ការ៉ាសជួសជុលរថយន្តនៅភ្នំពេញថា រថយន្ត០១គ្រឿងម៉ាក DODGE CHA LLENGER ពណ៌ខ្មៅ (បច្ចុប្បន្នបិតពណ៌ស) ជារបស់ពួកគេដែលបានគ្រោះថ្នាក់ចរាចរណ៍បុកគ្នាត្រូវយកទៅជួលជុលនៅភ្នំពេញ។ ចំពោះតៃកុងឡានស្ទូច ចំនួន២នាក់ និងម្ចាស់ការ៉ាស់ជួសជុលរថយន្ត ចំនួន១នាក់ ក្រោយពីជំនាញការិយាល័យព្រហ្មទណ្ឌកំរិតស្រាលធ្វើការសាកសួររួច ពួកគាត់ទាំង៣នាក់ មិនបានពាក់ព័ន្ធក្នុងករណីនេះ



Scanned with CamScanner

លួចរថយន្តនោះទេ កម្លាំងជំនាញការិយាល័យព្រហ្មទណ្ឌកំរិតស្រាល នៃការិយាល័យព្រហ្មទណ្ឌកំរិតស្រាល បានឱ្យវិលត្រឡប់ទៅវិញ ដោយមានការអនុញ្ញាតពីឯកឧត្តមព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

៣.៤ យោងតាមលទ្ធផលនៃការសួរដេញដោល តុលាការពិចារណាឃើញថា៖

- **អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] បញ្ញារិទ្ធ**
  - ផ្អែកតាមចម្លើយរបស់ជនជាប់ចោទបានឆ្លើយបញ្ជាក់ថា ខ្លួនត្រូវបានសមត្ថកិច្ចចាប់ខ្លួនដោយសារលួចឡានរបស់គេ ជាមួយឈ្មោះ [redacted] ដារិន ។ នៅថ្ងៃមិនចាំ ខែធ្នូ ឆ្នាំ២០២២ ខ្លួន និងឈ្មោះ [redacted] ដារិន បានជិះឡាន១គ្រឿង ម៉ាក PRIUS ពណ៌ខ្មៅ ផ្លាកលេខ ភ្នំពេញ 2BS-7303 (ជាឡានរបស់ឈ្មោះ [redacted] ដារិន ) ទៅដើរលេងនៅខេត្តព្រះសីហនុ ជាមួយគ្នា។ ពេលដែលមកដល់កំពង់សោម ពួកខ្លួនក៏នាំគ្នាជិះរថយន្តទៅហូបអី ពេលកំពុងធ្វើដំណើរនោះឈ្មោះ [redacted] ដារិន បានឃើញឡាន ០១គ្រឿង ម៉ាក DODGE CHALLENGER ពណ៌ខ្មៅ (បិតពណ៌ស) ដែលមានគ្រោះថ្នាក់ចរាចរណ៍ ចតចោលនៅចិញ្ចើមផ្លូវ ហើយគាត់ប្រាប់ថាស្រឡាញ់ឡាននេះ រួចហើយគាត់ក៏ឆែករកលេខឡានស្ទូចតាមរយៈហ្វេបុក និងទំនាក់ទំនងទៅឡានស្ទូច ជួលក្នុងតម្លៃ ៣០០$ ពេលឡានស្ទូចមកដល់ គាត់ប្រាប់ទៅម្ចាស់ឡានស្ទូចឱ្យជួយដឹកឡាននេះទៅភ្នំពេញ។ ពេលដឹកឡាននេះមកដល់ភ្នំពេញ គាត់ក៏បានទំនាក់ទំនងទៅម្ចាស់ការ៉ាស់ នៅម្តុំក្រាំងធ្នង់ ហើយឱ្យឡានស្ទូចទំលាក់ឡាននេះនៅទីនោះតែម្តង។ ដែលការអះអាងនេះតុលាការអាចជឿបាន ព្រោះស្របនឹងចម្លើយរបស់ជនរងគ្រោះថា នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ ពេលយកគ្រឿងបន្លាស់មកដើម្បីយកទៅប្តូរ ក៏ពុំឃើញរថយន្ត ហើយពេលឆែកកាំមេរ៉ាសុវត្ថិភាព ក៏ឃើញបុរស២នាក់លួចស្ទូចរថយន្តយកទៅ។
- **អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ដារិន**
  - ផ្អែកតាមចម្លើយរបស់ជនជាប់ចោទបានឆ្លើយបដិសេធថា ខ្លួន និងឈ្មោះ [redacted] បញ្ញារិទ្ធ ដែលត្រូវមិត្តភក្តិនឹងគ្នា ត្រូវបានសមត្ថកិច្ចចាប់ខ្លួន ដោយបានធ្វើសកម្មភាពលួចឡានរបស់គេនៅខេត្តព្រះសីហនុ។ នៅថ្ងៃមិនចាំ ខែធ្នូ ឆ្នាំ២០២២ ខ្លួនជាមួយនឹងឈ្មោះ [redacted] បញ្ញារិទ្ធ បានជិះតាមផ្លូវចេញពីកន្លែងហូបអី ពេលនោះក៏បានប្រទះឃើញរថយន្ត១គ្រឿង ម៉ាក DODGE CHALLENGER ពណ៌ខ្មៅ ប៉ុន្តែបិតស្អុតពណ៌ស ពុំឃើញមានស្លាកលេខនោះទេ និងមិនមានចាក់សោរដែរ បានចតចោលនៅចិញ្ចើមផ្លូវ មានបុកខូចផ្នែកខាងមុខ គ្របតង់ចោល។ ខ្លួនក៏ទំនាក់ទំនងឡានស្ទូច ដែលស្គាល់



Scanned with CamScanner

លេខតាមរយៈហ្វេសប៊ុក មកស្ទូចឡាននោះ ក្នុងតម្លៃ ៣០០$ រួចដឹកតាមផ្លូវល្បឿនលឿន យកមកភ្នំពេញ ពេលឡានស្ទូចមកដល់ ម្ចាស់ឡានស្ទូចក៏បានសួរពួកខ្លួនថា មិនផ្ញើនៅកំពង់សោម ខ្លួនក៏បានប្រាប់គាត់វិញថា ការ៉ាស់នៅកំពង់សោមគេមិនផ្ញើឱ្យ ហើយឡាននេះជារបស់ខ្លួន ពេលដឹកមកដល់ការ៉ាស់នៅភ្នំពេញ ម្ចាស់ការ៉ាស់បានសួរពួកខ្លួនថា ឡាននេះជារបស់អ្នកណា ខ្លួនក៏បានប្រាប់គាត់វិញថា ជាឡានរបស់បងខ្លួន បុកនៅកំពង់សោម គ្មានជាងធ្វើៗ ខ្លួនជាអ្នកផ្ដើមគំនិតក្នុងការលួចឡាននេះ ដែលការអះអាងនេះតុលាការអាចជឿបាន ព្រោះស្របនឹងចម្លើយរបស់ជនរងគ្រោះថា នៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០២២ យកគ្រឿងបន្លាស់មកដើម្បីយទៅប្ដូរ ក៏ពុំឃើញរថយន្ត ហើយពេលឆែកកាមេរ៉ាសុវត្ថិភាព ក៏ឃើញបុរស២នាក់លួចស្ទូចរថយន្តយកទៅ ចំណែកចម្លើយរបស់ឈ្មោះ [redacted] ដារិន ថាឈ្មោះ [redacted] បញ្ញារិទ្ធ មិនដឹងថាលួចឡានគេ ដោយខ្លួនប្រាប់ឈ្មោះ [redacted] បញ្ញារិទ្ធ ថា ជាឡានរបស់បងនេះ តុលាការពុំអាចជឿបានឡើយ ព្រោះនេះជាចម្លើយគ្មានកស្តុតាង និងពុំមានហេតុផលសមរម្យ ដោយហេតុថាឈ្មោះ [redacted] បញ្ញារិទ្ធ បានសារភាពទទួលស្គាល់កំហុសអស់ហើយថា ខ្លួនបានដឹងពីការលួចរថយន្តនេះដែរ។

- **អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ហេង និងឈ្មោះ [redacted] សុភក្តិ**
  - តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហេង , ឈ្មោះ [redacted] សុភក្តិ បានឆ្លើយនៅសមត្ថកិច្ចប្រហាក់ប្រហែលគ្នាថា ខ្លួនជាអ្នករកស៊ីឡានស្ទូច នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ ឈ្មោះ ផល (កន្លងមកធ្លាប់រកស៊ីឡានស្ទូចជាមួយគ្នា) ស្នាក់នៅរាជធានីភ្នំពេញ បានទំនាក់ទំនងមកខ្លួនតាមលេខទូរស័ព្ទ ០១២ ២០៧៣៣០ ដើម្បីរកឡានស្ទូចថាមានឡានខូចនៅខេត្តព្រះសីហនុ មានគេពឹងឱ្យគាត់ជួយរកឡានស្ទូចឱ្យ ហើយគាត់ក៏បានឱ្យលេខទូរស័ព្ទម្ចាស់ឡានខូចនោះមកពួកខ្លួន គាត់បានប្រាប់ពួកខ្លួនថា ម្ចាស់ឡានគេកំពុងចាំនៅទីតាំងឡានខូច ពួកខ្លួនក៏បានទំនាក់ទំនងទៅម្ចាស់ឡានខូចនោះ តាមរយៈលេខទូរស័ព្ទ ០១១ ៤០១៤៤៤ , ០១១២៥៩៦៦០ ហើយបាននិយាយតម្លៃជាមួយម្ចាស់ឡានខូចនោះ គាត់បានឱ្យខ្លួន ២៥០$ តែពួកខ្លួនទាគាត់ ៣០០$ ពេលនោះគាត់ក៏យល់ព្រម ហើយបានផ្ញើ Location ទីតាំងកន្លែងគាត់ខូចឡានតាមប្រព័ន្ធតេលេក្រាម នៅមុំសាលារៀន វេស្ទើន ស្ថិតនៅភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ចេញទៅយកឡានខូចនោះជាមួយគូឡានរបស់ខ្លួនឈ្មោះ [redacted] សុភក្តិ ដោយជិះឡាន១គ្រឿងម៉ាក HYUNDAI ពណ៌ស



Scanned with CamScanner

ស្លាកលេខ 3B-3590 ប្រភេទឡានស្ទូច៥តោន(ជាឡានរបស់ខ្លួន និងឈ្មោះ សុភក្តិ) ពេលទៅដល់ទីនោះ ពួកខ្លួនបានជួប និងបុរស២នាក់ ជាជនជាតិខ្មែរ ក្នុងនោះ១នាក់ពាក់ឯកសណ្ឋានសមត្ថកិច្ច និង១នាក់ទៀត ពាក់ស៊ីវិលធម្មតា មិនធ្លាប់ស្គាល់ គាត់បានប្រាប់ថា គាត់ជាម្ចាស់ឡាននោះម៉ាក DODGE CHALLENGER ពណ៌ស ស្លាកលេខ កម្ពុជា HEAXING5 ដែលឱ្យពួកខ្លួនស្ទូចយកទៅភ្នំពេញ ដើម្បីយកទៅផ្ញើ គាត់បានប្រាប់ថា ផ្ញើនៅខេត្តព្រះសីហនុ ថ្ងៃពេក ចឹងបានឱ្យដឹកយកទៅផ្ញើនៅរាជធានីភ្នំពេញ បានប្រហែលជាកន្លះម៉ោង ពួកខ្លួនក៏បានស្ទូចឡាននោះ ដាក់មកលើឡានរបស់ពួកខ្លួន ចេញទៅភ្នំពេញ ហើយពួកគាត់បានប្រាប់ថា ចេញទៅមុនទៅចាំគាត់ទៅតាមក្រោយ ពេលទៅដល់ភ្នំពេញចាំទាក់ទងគ្នា ប្រាប់កន្លែងដាក់ឡាន។ រហូតដល់ម៉ោង ០៩ និង០០នាទី ពួកខ្លួនបានទៅដល់ភ្នំពេញ ពួកគាត់បាននាំខ្លួនយកឡានទៅទំលាក់ នៅការ៉ាស់ឡាន១កន្លែង នៅម្តុំវត្តក្រាំងធ្នង់ ស្ថិតនៅសង្កាត់ក្រាំងធ្នង់ រាជធានីភ្នំពេញ ពួកគាត់បានជិះឡានម៉ាក PRUIS ពណ៌ខ្មៅ (មិនចាំស្លាក់លេខ) តាមពីក្រោយឡានរបស់ខ្លួន ពេលដែលទំលាក់ឡាននោះហើយ គាត់បានបាញ់លុយឱ្យមកខ្លួនតាមគណនី ABA ដែលមានឈ្មោះ [redacted] DARIN លេខគណនី: 225566000 ចំនួន ៣៦០$(បីរយសែមសិប)ដុល្លារអាមេរិក បូកទាំងឡើងផ្លូវល្បឿនលឿន ពេលដែលទទួលបានលុយហើយ ពួកខ្លួនក៏ត្រឡប់មកវិញជាមួយព្រូឡានរបស់ខ្លួន។ តាមចម្លើយអ្នកទាំងពីរ និងផ្អែកតាមចម្លើយរបស់ឈ្មោះ [redacted] ដារិន និងឈ្មោះ [redacted] បញ្ញារិទ្ធ បានបង្ហាញឱ្យឃើញថា ជាតុសត្យានុម័ត គឺអ្នកទាំងពីរបានស្ទូចយករថយន្តរបស់អ្នកដទៃ តាមការចង្អុលបង្ហាញរបស់ឈ្មោះ [redacted] ដារិន និងឈ្មោះ [redacted] បញ្ញារិទ្ធ មែន ប៉ុន្តែពុំមានសញ្ញាណាមួយបង្ហាញថា ជនជាប់ចោទទាំងពីរនាក់ ដឹងថា ឈ្មោះ [redacted] ដារិន និងឈ្មោះ [redacted] បញ្ញារិទ្ធ លួចរថយន្តរបស់គេឡើយ។ ជនជាប់ចោទទាំងពីរពុំមានចេតនាសម្រួលដល់អំពើលួចរបស់ឈ្មោះ [redacted] ដារិន និងឈ្មោះ [redacted] បញ្ញារិទ្ធ ឡើយ។

- **អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ប្រុស**
  - តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប្រុស បានឆ្លើយនៅសមត្ថកិច្ចថា នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ០៨ និង ០០នាទី ឈ្មោះ [redacted] ដារិន ប្រើប្រាស់លេខទូរស័ព្ទ ០៩៣ ៣០១០០៧ បានទាក់ទងមកខ្លួនប្រាប់ថាគាត់មាន



Scanned with CamScanner

ឡាន១គ្រឿងម៉ាក DODGE CHALLENGER ពណ៌ខ្មៅ(បិទពណ៌ស) បុកគ្រោះថ្នាក់ចរាចរណ៍នៅខេត្តព្រះសីហនុ ដាច់កង់១គ្រាប់ យកមកធ្វើនៅភ្នំពេញ ដាក់ឡានស្ទូចយកមកឱ្យជួលជុល ពេលនោះខ្លួនក៏បានប្រាប់ទីតាំង ការ៉ាសឡានរបស់ខ្លួនឱ្យទៅគាត់ ស្ថិតនៅម្តុំវត្តក្រាំងផ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ពេលលនោះគាត់រកទីតាំងមិនឃើញ ខ្លួនក៏បានដាក់ទីតាំង Location តាមប្រព័ន្ធតេលេក្រាមទៅឱ្យគាត់ បានប្រហែលជា១៥នាទី គាត់បានជិះឡាន ០១ គ្រឿងម៉ាក PRIUS ពណ៌ខ្មៅ ស្លាកលេខ ភ្នំពេញ 2BS-7303 (មានគ្នា២នាក់ ប្រុស) និង ឡាន១គ្រឿងទៀតជាប្រភេទឡានស្ទូច ដែលដឹកឡានដែលត្រូវយកមកទំលាក់ធ្វើនៅការ៉ាស់របស់ខ្លួន ពេលមកដល់ពួកគាត់ក៏បានទំលាក់ឡាននោះនៅមុខការ៉ាស ហើយរុញចូលទៅក្នុងការ៉ាស់ ហើយម្ចាស់ឡានស្ទូចនោះ ក៏បានបើកចេញពីការ៉ាសខ្លួនទៅវិញ ភ្លាមៗនោះឈ្មោះ [redacted] ដារិន គាត់ក៏បានបកស្កុតឡានពណ៌សនោះចេញ ឱ្យឃើញពណ៌ខ្មៅវិញ ហើយបាននិយាយជាមួយខ្លួន រឿងថ្លៃជួលជុលឡាននោះ តែខ្លួនបានប្រាប់ទៅគាត់វិញថា មិនមានគ្រឿងផ្លាស់ប្តូរទេ វាជាប្រភេទឡានទំនើប នៅស្រុកខ្មែរមិនមានគ្រឿងទេ ខ្លួនបានប្រាប់គាត់ទៀតថា ឱ្យកុម្ម៉ង់គ្រឿងខ្លួនឯងទៅ ខ្លួនជួយដូរ និងជួលជុលឱ្យ ព្រោះការ៉ាសរបស់ខ្លួនទទួលតែបាញ់ថ្នាំ គោន និងជួលជុលម៉ាស៊ីនទេ ពេលនោះគាត់បានប្រាប់វិញថា ចាំគាត់ជាអ្នកកុម្ម៉ង់គ្រឿងមក ឱ្យខ្លួនជួយដូរឱ្យគិតថ្លៃពលកម្មតាមនឹងទៅ ហើយគាត់ក៏បានត្រលប់ទៅវិញ ដែលការអះអាងនេះ តុលាការអាចជឿបាន ព្រោះតាមជាក់ស្តែងឈ្មោះ [redacted] ដារិន មិនស្គាល់ទីតាំងយានដ្ឋានជួលជុលរថយន្ត របស់ឈ្មោះ [redacted] ប្រុស ឡើយ ទាំងនេះសបញ្ជាក់ថា ឈ្មោះ [redacted] ប្រុស ពុំបានជួយសម្រួលដល់អំពីលួចរបស់ឈ្មោះ [redacted] ដារិន ឡើយ ដោយពុំមានធាតុផ្សំណាមួយបញ្ជាក់ថា ជាការសមគំនិតឡើយ។

៣.៥ តាមចម្លើយរបស់ជនជាប់ចោទ និងចម្លើយដើមបណ្តឹងថា ជនជាប់ចោទទាំងពីរនាក់បានឱ្យរថយន្តស្ទូចៗយករថយន្ត ពីយានដ្ឋាននៅខេត្តព្រះសីហនុយកទៅភ្នំពេញ ហើយសកម្មភាពរបស់ជនជាប់ចោទទាំងពីរនាក់ ក៏បានប្រព្រឹត្តដូចនេះមែន ដែរអំពើនេះជាអំពើដកហូតដោយទុច្ចរិត នូវទ្រព្យសម្បត្តិរបស់អ្នកដទៃ ក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដែលអំពើនេះត្រូវបានចាត់ជាអំពើលួច តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ហើយអំពើរបស់ជនជាប់ចោទទាំង២



Scanned with CamScanner

នាក់ ពុំមានការគាស់ទម្លុះទម្លាយឡើយ ដែលពុំត្រូវបានចាត់ជាអំពើលួចមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌឡើយ។

៣.៦ ដើម្បីធ្វើការផ្តន្ទាទោសជនជាប់ចោទ ឱ្យស្របនឹងអំពើរបស់ពួកគេបានប្រព្រឹត្ត តុលាការគប្បីកែប្រែបទចោទប្រកាន់ពីបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយការគាស់ទម្លុះទម្លាយ** ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧ ចំណុច២** នៃក្រមព្រហ្មទណ្ឌ មកជាបទ **អំពើលួច** ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៦** នៃក្រមព្រហ្មទណ្ឌ វិញ។

៣.៧ សកម្មភាពទាក់ទងនឹងអំពើលួច ត្រូវបានហាមឃាត់ដោយច្បាប់របស់ប្រទេសកម្ពុជា ដូច្នេះការដែលជនជាប់ចោទបានដឹងរួចហើយថា សកម្មភាពដែលខ្លួនបានធ្វើ គឺជាអំពើខុសច្បាប់ ប៉ុន្តែខ្លួននៅតែប្រព្រឹត្តនោះ គឺពិតជាស្តែងឱ្យឃើញអំពីចេតនាទុច្ចរិតពិតប្រាកដ របស់ជនជាប់ចោទក្នុងការប្រព្រឹត្តអំពើល្មើសដែលបានចោទប្រកាន់។

៣.៨ យោងតាមសំអាងហេតុខាងលើ ពិតជាបង្ហាញឱ្យឃើញពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] **បញ្ញាវិទ្ធ** និងឈ្មោះ [redacted] **ដារិន** ពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៦** នៃក្រមព្រហ្មទណ្ឌ។

៣.៩ យោងតាមសំអាងហេតុខាងលើ បង្ហាញឱ្យឃើញថា ពុំមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោ[redacted]**ហេង** ,ឈ្មោះ [redacted] **សុភក្តិ** និងឈ្មោះ [redacted] **ប្រុស** ពីបទ **សមគំនិតក្នុងអំពីលួចមានស្ថានទម្ងន់ទោសដោយការគាស់ទម្លុះទម្លាយ** ប្រព្រឹត្តនៅភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ ,មាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌឡើយ ដូចនេះតុលាការគប្បីឱ្យជនជាប់ចោទទាំង៣នាក់ រួចផុតពីបទចោទប្រកាន់ ពីបទ **សមគំនិតក្នុងអំពីលួចមានស្ថានទម្ងន់ទោសដោយការគាស់ទម្លុះទម្លាយ**។

៣.១០ វត្ថុចាប់យករួមមាន៖

- រថយន្តចំនួន០១គ្រឿង ម៉ាក PRIUS ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 2BS-[redacted]



Scanned with CamScanner

7303 ។

- ទូរស័ព្ទដៃចំនួន០២គ្រឿង (ម៉ាក IPHONE 12 PRO ពណ៌ខ្មៅ និងម៉ាក IPHONE 14 PRO MAX ពណ៌ស្វាយ) ។
- ប័ណ្ណសម្គាល់ខ្លួនមន្ត្រីនគរបាល ចំនួន០១សន្លឹក ។
- ប័ណ្ណចាក់វ៉ាក់សាំងការពារកូវីដ-១៩ ចំនួន០១សន្លឹក ។
- កាបូបលុយពណ៌ស្វៃ ចំនួន០១ ។
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចំនួន០១សន្លឹក ។
- ប័ណ្ណសមាជិក ប.ស.ស ចំនួន០១សន្លឹក ។
- កាតធនាគារ ABA ចំនួន០១សន្លឹក ។
- កាត NAGA WORLD ចំនួន០១សន្លឹក ។

ជាសម្ភារៈផ្ទាល់ខ្លួនរបស់ជនជាប់ចោទ គប្បីតុលាការសម្រេចប្រគល់ឱ្យម្ចាស់ដើមយកទៅប្រើវិញ ។

៣.១១ តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ទ្រង់តាមការសាកសួរនាពេលសវនាការចំពោះអង្គហេតុខាងលើ ពុំមែនជាអំពើលួចមានស្ថានទម្ងន់ទោសទេ វាជាអំពើលួចធម្មតា ដូចនេះតំណាងអយ្យការសុំធ្វើការកែប្រែបទចោទលើជនជាប់ចោទឈ្មោះ [redacted] បញ្ញារិទ្ធ និងឈ្មោះ [redacted] ដារិន ពីបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយការគាស់ទម្លុះទម្លាយ** មកជាបទ **អំពើលួច** តាមបញ្ញត្តិមាត្រា ៣៥៣ ,៣៥៦ នៃក្រមព្រហ្មទណ្ឌ ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] ហេង ,ឈ្មោះ [redacted] សុកក្តិ និងឈ្មោះ [redacted] ប្រុស ពុំបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ សុំឱ្យរួចផុតបទចោទ ដែលការសន្និដ្ឋាននេះស្របតាមអំពើរបស់ជនជាប់ចោទ គប្បីតុលាការលើកយកមកពិចារណា និងសម្រេចតាមការប្តឹងសុំរបស់តំណាងអយ្យការ។

៣.១២ មេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] បញ្ញារិទ្ធ និងជនជាប់ចោទឈ្មោះ [redacted] ដារិន បានធ្វើសេចក្តីសន្និដ្ឋានថា សុំកែប្រែបទចោទលើកូនក្តីខ្លួនឈ្មោះ [redacted] បញ្ញារិទ្ធ និងឈ្មោះ [redacted] ដារិន ពីបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយការកាប់គាស់ទម្លុះទម្លាយ** តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ ចំណុច២ នៃក្រមព្រហ្មទណ្ឌទៅជាបទ **អំពើលួច** ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ វិញ។ គប្បីតុលាការលើកយកមកពិចារណា តាមការសន្និដ្ឋានរបស់តំណាងអយ្យការ។



Scanned with CamScanner

៣.១៣ មេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហេង ,ជនជាប់ចោទឈ្មោះ [redacted] សុភក្តិ និងជនជាប់ចោទឈ្មោះ [redacted] ប្រុស បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនឈ្មោះ [redacted] ប្រុស ជាអ្នករកស៊ីបើកកាំសជួសជុលឡានតែប៉ុណ្ណោះ។ រីឯកូនក្តីខ្លួនឈ្មោះ [redacted] ហេង និងឈ្មោះ [redacted] សុភក្តិ គឺពួកគាត់រកស៊ីជាអ្នកស្ទូចរថយន្ត ពាក់ព័ន្ធនឹងការលួចរថយន្តនោះ កូនក្តីខ្លួនទាំង៣នាក់ពុំបានដឹងឡើយ។ ដូច្នេះខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំង៣នាក់ខាងលើ ស្នើសុំឱ្យតុលាការលើកលែងចោទប្រកាន់ឱ្យកូនក្តីខ្លួនទាំង៣នាក់ខាងលើផង។ គប្បីតុលាការលើកយកមកពិចារណា តាមការសន្និដ្ឋានរបស់តំណាងអយ្យការ។

៣.១៤ ជនជាប់ចោទឈ្មោះ [redacted] បញ្ញារិទ្ធ និងជនជាប់ចោទឈ្មោះ [redacted] ដារិន បាននិយាយសំដីចុងក្រោយថា សុំតុលាការជួយបន្ធូរបន្ថយទោសឱ្យពួកខ្លួនផង។ គប្បីតុលាការលើកយកមកពិចារណា ព្រោះឈ្មោះ [redacted] បញ្ញារិទ្ធ បានទទួលស្គាល់កំហុសហើយ។

៣.១៥ កម្រិតនៃទណ្ឌកម្ម ដែលមានកំណត់ក្នុងមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ មានកម្រិតចាប់ពី ៦(ប្រាំមួយ)ខែ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ៦.០០០.០០០(ប្រាំមួយលាន)រៀល ដូច្នេះគប្បីតុលាការពិចារណាអំពីការប្រកាសទោស ក្នុងកម្រិតដែលមានកំណត់នេះ ដោយពិចារណាផ្អែកលើចរិកលក្ខណៈ នៃអំពើដែលរងការចោទប្រកាន់ រួមជាមួយកាលៈទេសៈបទល្មើស និងបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ស្របតាមគោលការណ៍ឯកត្តកម្ម នៃទោសតាមបញ្ញត្តិមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ ។

៣.១៦ ដើមបណ្តឹងរដ្ឋប្បវេណីពុំបានចូលខ្លួនមកតាំងខ្លួនជាដើមបណ្តឹង និងធ្វើការទាមទារសំណងក្នុងរឿងព្រហ្មទណ្ឌនេះទេ ដូច្នេះតុលាការគប្បីទុកសិទ្ធិជូនដើមបណ្តឹង ប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីនាពេលក្រោយតាមច្បាប់។

## ៤.ផ្នែកសេចក្តីសម្រេច ៖

## ហេតុដូច្នេះសាលាដំបូងខេត្តព្រះសីហនុ

## វិនិច្ឆ័យសេចក្តី

៤.១- **ឱ្យរួចខ្លួន**ពីបទចោទលើឈ្មោះ [redacted] **ហេង** ភេទប្រុស កើតឆ្នាំ១៩៨៥ ជនជាតិខ្មែរ , ឈ្មោះ [redacted] **សុភក្តិ** ភេទប្រុស កើតឆ្នាំ១៩៨៧ ជនជាតិខ្មែរ និងឈ្មោះ [redacted] **ប្រុស** ភេទប្រុស កើតឆ្នាំ១៩៧៩ ជនជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ)៖

ពីបទ **សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយការគាស់ទម្លុះទម្លាយ** ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

៤.២- កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] **បញ្ញារិទ្ធ** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] **ដារិន** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ពីបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយការគាស់ទម្លុះទម្លាយ** ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ ចំណុច២ នៃក្រមព្រហ្មទណ្ឌ មកជាបទ **អំពើលួច** ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៤.៣- **ផ្តន្ទាទោស**លើឈ្មោះ [redacted] **បញ្ញារិទ្ធ** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល **១០(ដប់)ខែ** និងពិន័យជាប្រាក់ចំនួន **២.000.000(ពីរលាន)រៀល** សម្រាប់ដាក់ចូលជាថវិការដ្ឋ ៖

ពីបទ **អំពើលួច** ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៤.៤- ឈ្មោះ [redacted] **ដារិន** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល **១(មួយ)ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **៣.000.000 (បីលាន)រៀល** សម្រាប់ដាក់ចូលថវិការដ្ឋ ៖

ពីបទ **អំពើលួច** ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៤.៥- **វត្ថុចាប់យកត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ រួមមាន៖**

- រថយន្តចំនួន០១គ្រឿង ម៉ាក PRIUS ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 2BS-7303 ។
- ទូរស័ព្ទដៃចំនួន០២គ្រឿង (ម៉ាក IPHONE 12 PRO ពណ៌ខ្មៅ និងម៉ាក IPHONE 14 PRO MAX ពណ៌ស្វាយ ) ។
- ប័ណ្ណសម្គាល់ខ្លួនមន្ត្រីនគរបាល ចំនួន០១សន្លឹក ។
- ប័ណ្ណចាក់វ៉ាក់សាំងការពារកូវីដ-១៩ ចំនួន០១សន្លឹក ។
- កាបូបលុយពណ៌ស្វៃ ចំនួន០១ ។
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចំនួន០១សន្លឹក ។



Scanned with CamScanner

- ប័ណ្ណសមាជិក ប.ស.ស ចំនួន០១សន្លឹក ។
- កាតធនាគារ ABA ចំនួន០១សន្លឹក ។
- កាត NAGA WORLD ចំនួន០១សន្លឹក ។

**សាលក្រម**នេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] បញ្ញារិទ្ធ , ឈ្មោះ [redacted] ដារិន កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហេង ,ឈ្មោះ [redacted] សុភក្តិ ,ឈ្មោះ [redacted] ប្រុស និងដើមបណ្តឹងរដ្ឋប្បវេណី។

-ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា: [redacted]

**ក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃសុក្រ ១៥កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តព្រះសីហនុ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣

**បានឃើញ**

**ប្រធានក្រុមប្រឹក្សា**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner